**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៩១...សសរ

**សេចក្តីសំរេច**

**ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំ រេ ច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួម កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ៦ នៅទីក្រុងហែលស៊ីនគី សាធារណរដ្ឋហ្វាំងឡង់ដ៍ ចាប់ពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៦ រហូតដល់ សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ២*

*-ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com